លុះឯក្រោយទៀត លឺល្បីទៅដល់ស្រុកចិនថា ស្រុកខ្មែរមានអ្នកប្រាជ្ញម្នាក់មានប្រាជ្ញាណាស់ មិនមានអ្នកឯណានឹងផ្ចាញ់ប្រាជ្ញាមាន ស្តេចស្រុកចិនគិតនឹងអស់នាម៉ឺនថា យើងនឹងគិតធ្វើចំនោទទៅអោយអ្នកប្រាជ្ញស្រុកខ្មែររក ស្តេចក្រុងចិន និងអស់នាម៉ឺនអោយរកផ្លែឪឡឹក៣ ត្បិតពូជឪឡឹកក្នុងស្រុកចិននោះមាន៣យ៉ាង មួយយ៉ាងនោះក្នុងផ្លែ១ មានគ្រាប់តែ១ ផ្លែ១ទៀតមានគ្រាប់ពីរ ផ្លែ១ទៀតមានគ្រាប់បី ស្តេចស្រុកចិនអោយរៀបសំពៅទាំង៥០០ ក្នុងសំពៅ១ មានចិន៥០០ជាចំនុះសំពៅគ្រប់ទាំង៥០០សំពៅ ហើយធ្វើសំបុត្ររាជសារ ក្នុងសេចក្តីសំបុត្រថា ត្បិតស្រុកខ្មែរមានអ្នកប្រាជ្ញមានប្រាជ្ញាណាស់ ឈ្មោះធនញ្ជ័យ បើដូច្នេះស្តេចស្រុកចិនអោយនាំផ្លែឪឡឹកបីមកនឹងសំពៅ៥០០ ក្នុងសំពៅមួយៗមានមនុស្ស៥០០គ្រប់សំពៅនាំមកអោយអ្នកប្រាជ្ញស្រុកខ្មែរទាយផ្លែឪឡឹកទាំងបីនេះ ថាឪឡឹក១មានគ្រាប់ប៉ុន្មាន បើអ្នកប្រាជ្ញស្រុកខ្មែរទាយត្រូវ នោះយើងភ្នាល់ដាក់សំពៅទាំង៥០០នឹងមនុស្សទាំងអស់ក្នុងចំនុះសំពៅនោះផង បើអ្នកប្រាជ្ញស្រុកខ្មែរទាយមិនត្រូវ យើងនឹងយកស្រុកខ្មែរលុះធ្វើសុភអក្សររួចហើយ អោយនាម៉ឺនធំម្នាក់ និងអ្នកប្រាជ្ញម្នាក់នាំចេញមក លុះមកដល់ហើយ នាម៉ឺនចិននាំសំបុត្រឡើងក្រាបទូលស្តេចស្រុកខ្មែរៗអោយហៅធនញ្ជ័យមកប្រាប់ថា ឥលូវនេះ ស្តេចស្រុកចិននាំសារមកថា អោយទាយផ្លែឪឡឹកក្នុងផ្លែ១ តើមានគ្រាប់ប៉ុន្មាន បើអាឯងទាយត្រូវក៏ហើទៅ បើអាឯងទាយមិនត្រូវអញនឹងយកទោសដល់ជីវិត។ ធនញ្ជ័យលឺហើយក្រាបទូលថា កុំព្រួយព្រះរាជហឫទ័យធានាទូលបង្គំទាយអោយត្រូវ ប៉ុន្តែក្នុងចិត្តធនញ្ជ័យភ័យណាស់ ដែលបានជាអួតថាជាអ្នកប្រាជ្ញមានប្រាជ្ញាយូរមកហើយៗធនញ្ជ័យលាទៅផ្ទះវិញ លុះទៅដល់ផ្ទះធនញ្ជ័យដេកគិតរកប្រាជ្ញានិងទាយផ្លែឪឡឹកនោះ ដេកអត់បាយអំពីព្រឹក លុះគ្រាតែល្ងាច ហើយធនញ្ជ័យនឹងគិតរកមិនឃើញ ក៏



គិតថា : ឥលូវនេះ ស្តេចអោយដោះប្រស្នានឹងស្តេចក្រុងចិន បើដោះមិនរួច ស្តេចនឹងសំលាប់ បើដូច្នេះអញគង់តែនឹងស្លាប់ អញមុជទឹកអោយស្លាប់ទៅទើបជា។ លុះដល់ព្រលប់យប់ងងឹត ធនញ្ជ័យចុះទៅកំពង់ទឹក ហើយចុះទៅមុជ ដើម្បីអោយស្លាប់ក្នុងទឹក ដល់មុជទឹកទៅចេះអណ្តែតខ្លួនឡើង ហើយរសាត់ទៅដល់ចង្កូតសំពៅចិន ធនញ្ជ័យកាន់ចង្កូតសំពៅនោះបានលឺនាម៉ឺនចិន និងអ្នកប្រាជ្ញស្រុកចិននិយាយគ្នានៅក្នុងបាតសំពៅថា បើយើងធ្វើប្រស្នាឪឡឹកហើយ តើយើងធ្វើប្រស្នាអ្វីតទៅទៀត ត្បិតឪឡឹកនេះផ្លែវាតែបី ផ្លែ១គ្រាប់១ ផ្លែ១ទៀតគ្រាប់២ ផ្លែ១ទៀតគ្រាប់៣ប៉ុណ្ណោះ យើងគិតធ្វើប្រស្នាពីរបីយ៉ាងទៀតបំណាច់ស្តេចប្រើមក បើវេ ាយត្រូវមួយយ៉ាង នៅមួយយ៉ាងទៀត កុំអោយតែមួយយ៉ាងហើយអស់ទៅតែម្តង ហាក់ជាប្រាជ្ញយើងតិចណាស់ ឯអ្នកប្រាជ្ញស្រុកចិនឆ្លើយឡើងថា យើងចំនោទពីរបីយ៉ាងទៀត។ នាម៉ឺនអស់នោះសួរថា ចំនោទអ្វីទៀត។ អ្នកប្រាជ្ញថា យើងនិយាយគ្នានេះ កុំអោយនរណាដឹងក្រែងមានមនុស្សមកលបស្តាប់ ហើយនាម៉ឺន និងអ្នកប្រាជ្ញរកមើលមនុស្សគ្មាន ក៏បបួលគ្នានិយាយពីប្រស្នាពីបីយ៉ាងនោះ អ្នកប្រាជ្ញនិយាយថា យើងយកសាច់ជ្រូក១នាឡិ អោយស្តេចស្រុកខ្មែរទុកសោយបានពីរឆ្នាំ កុំអោយប្រឡាក់អំបិល កុំអោយធ្វើងៀត អោយទុកជាសាច់ស្រស់ស្តេចសោយបានពីរបីឆ្នាំកុំអោយស្អុយខូច នាម៉ឺនសួរថា ធ្វើដូចម្តេចនឹងបានពីរឆ្នាំ សាច់ជ្រូក១នាឡិប៉ុណ្ណោះ។ អ្នកប្រាជ្ញឆ្លើយថា បើដល់ជិតថ្ងៃនឹងជាប់ឆ្នាំ នឹងចូលឆ្នាំថ្មី យើងយកសាច់ជ្រូកមកទុកស៊ីតែពីរបីថ្ងៃក៏រាប់ជាពីរឆ្នាំ ត្បិតឆ្នាំចាស់មួយថ្ងៃ ឆ្នាំថ្មីមួយថ្ងៃ ត្រូវជាពីរឆ្នាំ បើអ្នកប្រាជ្ញស្រុកខ្មែររកមិនឃើញយើងនឹងយកនគរជាចំនុះយើង។មួយទៀតនោះ យើងអោយមនុស្សចាប់ចាបមួយមក ហើយយកទៅអោយស្តេចស្រុកខ្មែរ អោយរៀបធ្វើសម្លយកមកអោយពលយើងក្នុងសំពៅទាំង៥០០ស៊ីអោយឆ្អែត នាម៉ឺនទាំងអស់នោះ





សួរថា ដូចម្ដេចសត្វតូច១ ហើយយកទៅធ្វើសម្លម្ហូបមកអោយពលយើងទាំងអស់ស៊ីអោយឆ្អែតបាន អ្នកប្រាជ្ញនោះប្រាប់ថា បើគេមានប្រាជ្ញ គេអោយយកម្ទូលមកអោយយើងដំធ្វើជាពូថៅធំ១ និងយកទៅពុះចាបយកសាច់ស្លអោយពលស៊ី ។ មួយទៀតយើងបង្គាប់ស្ដេចស្រុកខ្មែរអោយធ្វើយុត្កាបាន៥០ និងយកមកបោះចតសំពៅយើងអោយគ្រប់៥០០ អោយធ្វើក្នុងថ្ងៃមួយអោយរួច ក្នុងយុត្កា១ទំហំ៣ចាប់ ។ នាម៉ឺនសួរថា ធ្វើដូចម្ដេចនឹងធ្វើយុត្កាដល់៥០០អោយរួចក្នុង១ថ្ងៃនោះ ។ អ្នកប្រាជ្ញនោះថា អោយយកចំបើងមកចងធ្វើជារាងយុត្កាហើយដាក់លើដី យកភ្លើងដុតអោយឆេះទៅនៅតែផេះចំបើងជាប់និងដី ហើយហៅមនុស្សអោយមកសែងយកទៅបោះចងសំពៅ បើជាអ្នកប្រាជ្ញមែន ធ្វើយ៉ាងនេះ ទើបទល់ប្រាជ្ញគ្នាបាន ។ ឯនាម៉ឺនលឺអ្នកប្រាជ្ញប្រាប់សព្វគ្រប់ដូច្នោះ មានចិត្តត្រេកអរណាស់ ថាស្រុកខ្មែរមុខជាបានកណ្ដាប់ដៃយើងមិនខានទេ ។ ឯធនញ្ជ័យតោងចង្កូតសំពៅចាំប្រុងត្រចៀកស្ដាប់សព្វគ្រប់គ្មានខ្វះឡើយ ដល់នាម៉ឺន និងអ្នកប្រាជ្ញស្រុកចិនលែងនិយាយគ្នា ធនញ្ជ័យមុជហែលមកឯកំពង់វិញ ហើយដើរឡើងទៅលើផ្ទះ មានចិត្តអរណាស់ គិតថាអញអស់ស្លាប់នេះគឺទេវតាជួយអញមិនអោយស្លាប់ លុះវេលាកាលណា នាម៉ឺនចិន និងអ្នកប្រាជ្ញយកផ្លែឪឡឹកទាំងបីឡើងអំពីសំពៅ ចូលទៅគាល់ស្ដេចស្រុកខ្មែរ ក្នុងព្រះរាជវាំង ស្ដេចអោយហៅធនញ្ជ័យប្រជុំអស់នាម៉ឺនមុខមន្ត្រីពាសពេញក្នុងព្រះរាជវាំង នាម៉ឺនចិន និងអ្នកប្រាជ្ញចិនយកផ្លែឪឡឹកទាំងបីមកអោយធនញ្ជ័យទាយ ឯធនញ្ជ័យទាយត្រូវទាំងអស់ ។ អ្នកប្រាជ្ញស្រុកចិន លុះដល់ធនញ្ជ័យដោះចំនោទស្រុកចិនដូចយើងនិយាយមកពីមុនគ្មានសល់តិចឡើយ ។ ស្ដេចខ្មែរជ្រាប អ្នកប្រាជ្ញចិនទល់ប្រាជ្ញនឹងធនញ្ជ័យ ទ្រង់អោយយកសំពៅទាំង៥០០ទុកតែសំពៅ១អោយនាម៉ឺន និងអ្នកប្រាជ្ញចិនត្រលប់ទៅស្រុកចិនវិញ ហើយស្ដេចប្រទានរង្វាន់អោយធនញ្ជ័យជាច្រើន ឯស្ដេចស្រុកចិនពីថ្ងៃនេះមក ខ្លាចប្រាជ្ញធនញ្ជ័យមិនហ៊ានអោយមកចោទប្រស្នាទៀត ប៉ុន្តែនឹកខ្វាល់ក្នុងព្រះទ័យថាបើឥតពីធនញ្ជ័យទៅកាលណា នឹងអោយភ្នាល់ចោទប្រស្នាទៀត ។

លុះឯក្រោយមកទៀត ស្ដេចស្រុកខ្មែរទ្រង់ព្រះចិន្តាគិតដល់សេចក្ដី

ធនញ្ជ័យផ្ទាញ់ប្រាជ្ញជាច្រើន ហើយក្រែងធនញ្ជ័យ ធនញ្ជ័យនៅជិតវាំង ដណ្តើមយករាជសម្បត្តិ ត្បិតធនញ្ជ័យមានប្រាជ្ញាច្រើនណាស់ ស្តេចមានព្រះបន្ទូលថា អាជ័យឯងនៅស្រុកនេះមិនបានទេ អញអោយអាឯងទៅនៅទន្លេ មានស្រុកណានៅប្របទន្លេទៅនៅតាមចិត្តអាឯង កុំនៅក្នុងស្រុកនេះឡើយ ធ្មញ្ជ័យស្តាប់ព្រះបន្ទូលហើយ ក្រាបថ្វាយបង្គំលាទៅដល់ផ្ទះហើយ និយាយប្រាប់ម្តាយថា ហ្លួងមានព្រះបន្ទូលប្រើខ្ញុំអោយទៅនៅតាមមាត់ទន្លេ អោយធ្វើស្រែរកស៊ីតាមចិត្ត ឯទន្លេនោះអោយជារបស់ខ្ញុំហើយ ឯម្តាយស្តាប់ហើយក៏ថាបើដូច្នោះកូនទៅនៅតាមព្រះបន្ទូលចុះ ឯខ្លួនម្តាយនៅផ្ទះនេះហើយ ធនញ្ជ័យស្តាប់ម្តាយហើយ ក៏លាម្តាយទៅប្រាប់អស់នាម៉ឺន នូវអស់រាស្ត្រប្រជាដែលនៅក្នុងមាត់ទន្លេថា ត្បិតហ្លួងមានព្រះបន្ទូលអោយអញជាធំ ស្រដីក្នុងទន្លេទាំងអស់នឹងធ្វើស្រែស្រូវ ឥលូវនេះ អញប្រាប់អ្នករាល់គ្នា បើដើរជើងទឹកអោយប្រាប់អញ អញនឹងកត់ជាថ្លៃទន្លេ និងព្រៃក ទូកដែលរកស៊ីសព្វថ្ងៃនេះ ព្រះរាជទ្រព្យអំពីថ្ងៃនេះទៅ បើអ្នកឯណាមិនបានចូលមកប្រាប់អញ និងបានសេចក្តីខុស អញនឹងធ្វើទោសតាមច្បាប់មិនប្រណីឡើយ ហើយធ្មញ្ជ័យយកដើមឫស្សីមកពុះជាចំរៀកតូចៗ ត្បាញជាភ្នែកក្រួចកាត់ជា៨ជ្រុង ហើយយកឫស្សីមួយដើមវែងចងដាក់លើចុងឫស្សី រួចយកស្លឹកត្នោតដេរជាកណ្តប ហើយកាត់ជាស្លាបទង់ជ័យដោតលើចុងឫស្សីធ្វើឃ្នាងតូច១ យកផ្តៅធ្វើជារំពាត់ ចងព្យួរជាមួយតម្បាញភ្នែកក្រួចនោះឯង បញ្ឈរឡើង ហើយធ្មញ្ជ័យប្រាប់ថា នេះឈ្មោះត្របែងដៃ អោយចូលប្រាប់គយ បើរាស្ត្រណាដើរជួញប្រែរកស៊ីឃើញត្របែងនេះ ដៃគយអោយចូលប្រាប់ទើបរួចទោស ប្រាមប្រាប់ដូច្នោះហើយ ក៏ចុះទូកចែវមើលតាមមាត់ទន្លេ ទីណាមានព្រៃក កំពង់ណាល្មមធ្វើស្រូវប្រាំងបាន លុះមើលជុំវិញហើយ មកកត់សំគាល់អោយឈ្មោះនៅស្ទឹងបារាយណ៍ទឹកថ្លា ស្ទឹង១ទៀតចុះមកក្នុងទន្លេ



អោយឈ្មោះចុងខ្មៀស មានជ្រោយ១ឈ្មោះជ្រោយស្លាព្រាហ្មណ៍ ទើបមានព្រៃក១ឈ្មោះថា កំពង់ចាម មានព្រៃក១ទៀតឈ្មោះកំពង់ភ្លុក ព្រៃក១ទៀត ឈ្មោះស្ទឹងព្រំស្រុក ព្រៃក១ទៀតនៅថាស្ទឹងក្រែង មានជ្រោយ១ទៀតឈ្មោះពេជត្រី មានព្រៃកមួយទៀតឈ្មោះពាមបាំង មានជ្រោយ១ទៀតហៅប្រទាស់នេះ មានបន្ទិច១ឈ្មោះបន្ទិចច្រកែង នៅបន្ទិចច្រកែងនោះខាងមាត់ទន្លេឈ្មោះនាងសៅ មានព្រៃកឈ្លូងប្រទល់មាត់ទន្លេនោះឈ្មោះបាយក្អែក មានកោះ១ទៀត ឈ្មោះកោះថ្កាល់បើស មានព្រៃក១ទៀតឈ្មោះព្រៃកខ្សាច់ មានស្ទឹង១ ឈ្មោះពាមសែន មានព្រៃក១ ឈ្មោះផាត់សណ្តាយ មានព្រៃក១ ឈ្មោះព្រៃកស្ងួត មានព្រៃក១ទៀត ឈ្មោះផ្លូវទូក មានកោះ១ ឈ្មោះកោះក្អែមានព្រៃក២ ឈ្មោះព្រៃកគួរ ១ព្រៃកប្រមាល់១ មានព្រៃក១ ឈ្មោះប្រឡាយមាស មានព្រៃក១ទៀតឈ្មោះព្រៃកក្អែក មានព្រៃក១ ឈ្មោះព្រៃកចក្រវត្តិ មានព្រៃកឈ្មោះព្រៃកកំបោងយោងទឹក មានព្រៃកមួយទៀត ឈ្មោះព្រៃកខ្យុច មានព្រៃក១ទៀតឈ្មោះព្រៃកអារ៉ង់ មានកំពង់មួយឈ្មោះកំពង់អូរមានកំពង់មួយទៀត ឈ្មោះកំពង់ខ្សាច់ស មានកោះ១ទៀត ឈ្មោះកោះកញ្ចាំនតូច មានកំពង់មួយទៀត ឈ្មោះកំពង់ព្រះមាន មានកំពង់១ទៀតឈ្មោះកំពង់អណ្តូង មានកោះ១ទៀតឈ្មោះកោះឆ្នុកទ្រូ មានព្រៃក១ ឈ្មោះព្រៃកស្លាមធ្លក មានកំពង់១ ឈ្មោះកំពង់ស្វាយក្រអែ មានជ្រោយ១ ឈ្មោះជ្រោយព្រះផ្តៅ មានកំពង់១ ឈ្មោះកំពង់ខ្សាច់ល្អិត មានកំពង់១ ឈ្មោះកំពង់ផ្លូវធំ មានជ្រោយ១ ឈ្មោះជ្រោយចាហីង មានកំពង់១ ឈ្មោះកំពង់ហ្លួង មានកំពង់១ ឈ្មោះកំពង់ប្រាក់ មានកំពង់១ឈ្មោះកំពង់ទួល មានស្ទឹង១ ឈ្មោះពាមព្រះស្ទឹង មានជ្រោយ១ ឈ្មោះជ្រោយសន្លុងតិច១ ឈ្មោះសន្លុងធំ មានជ្រោយ១ ឈ្មោះជ្រោយស្លាបស្ទាំង មានជ្រោយ១ ឈ្មោះជ្រោយកញ្ចាំនធំ មានស្ទឹង១ឈ្មោះស្ទឹងដូនទ្រី មាន

ស្ទឹង១ ឈ្មោះពាមមាត់ពីរ អោយជុំទន្លេ ហើយធនញ្ជ័យវិលមកឯកំពង់ប្រាក់វិញមើលទីនឹងធ្វើស្រែ ហើយដើរឡើងទៅព្រៃមើលស្ទឹងនោះ ល្មមនឹងធ្វើស្រែបាន ទឹកមានច្រើនបានជាអោយឈ្មោះបរិបូណ៌ អំពីថ្ងៃនោះឯង ទើបអោយទួល១ ជាងកើតស្ទឹងខាងត្បូង ឈ្មោះទួលរកា ខាងត្បូងទួលរកានោះមានវាល១ធំ ល្មមធ្វើស្រែសាបបាន បានជាអោយឈ្មោះថា វាលអង្កាម ត្បិតធនញ្ជ័យយកអង្កាមទៅសាបពេញវាលនោះឯង ឯទន្លេនោះធនញ្ជ័យហៅថាវាលភក់ ហើយយកអង្កាមទៅបាចពេញទន្លេនោះឯង ហើយគាត់អោយហៅឈ្មោះថាទន្លេសាប ហើយធនញ្ជ័យអោយហាមប្រាមថា បើនរណាចែវទូកអោយប្រយ័ត្នក្រែងវាខូចសំណាបអញ បើមិនស្តាប់អញនឹងចាប់អោយសង ហើយលក់ជាប្រាក់តម្លឹង៣០ដាច់សូវិលខ្លួន ១ទូក១ ។

ឯអស់រាស្ត្រចែវរកស៊ីក្នុងទន្លេនោះជាច្រើន នឹងចែវទៅឯណាអោយចៀសពីសំណាបនោះមិនបាន ធនញ្ជ័យក៏ចាប់ទូកអំបាលនោះថា ចែវចូលក្នុងសំណាប លក់យកប្រាក់បានទូក ១ជាប្រាក់៣០នោះឯង ឯអស់រាស្ត្រនោះខឹងហើយបបួលគ្នាឡើងទៅក្រាបទូលថា ត្បិតធនញ្ជ័យធ្វើស្រែក្នុងទន្លេនោះហើយយកអង្កាមទៅបាចពេញអស់ទន្លេ ហើយប្រាមប្រាប់អស់យើងខ្ញុំថា កុំអោយចូលក្នុងសំណាបនោះ បើចូលនឹងចាប់លក់យកជាប្រាក់តម្លឹងទូល១ បើដូច្នេះយើងខ្ញុំពុំសុខចិត្តឡើយ សូមមេត្តាអោយកោះធនញ្ជ័យមកជំនុំអោយខានបានដឹងដំនើរ ត្បិតយើងខ្ញុំមិនដែលលឺព្រះបន្ទូលថា មានច្បាប់ចាប់លក់យកប្រាក់ហួតយកពន្ធរទេះគ្រប់ទំនិញ ក្នុងព្រះនគរ ដូចធនញ្ជ័យថានោះទេ ព្រះមហាក្សត្រស្តាប់ហើយក៏ខ្ពល់ព្រះហឫទ័យនឹងធនញ្ជ័យណាស់ ហើយត្រាស់ប្រើអាមាត្យ១នាក់ថា អាឯងទៅហៅអាជ័យមកអោយឆាប់ កុំបង្អង់យូរឡើយ អាមាត្យស្តាប់ព្រះបន្ទូលហើយក៏ក្រាបថ្វាយបង្គំលាដើរទៅរកធនញ្ជ័យ ឃើញហើយក៏ប្រាប់ថា ត្បិតមានព្រះបន្ទូលពិសេស



អោយមកហៅធនញ្ជ័យឯង អោយទៅជាមួយនឹងយើង ជាព្រះរាជបំរើនេះ កុំអោយខានឡើយ បើខាននឹងខុសធនញ្ជ័យឯង ធនញ្ជ័យស្តាប់ហើយក៏ស្លៀកពាក់សំពត់អាវ រួចហើយក្តដើរទៅជាមួយនឹងបំរើនោះឯង លុះទៅដល់ហើយ ក៏ចូលទៅក្រាបថ្វាយបង្គំគាល់ស្ងៀមនៅ ចាំស្តាប់ព្រះបន្ទូល ។ ឯព្រះមហាក្សត្រទតឃើញធនញ្ជ័យមកដល់ហើយ ក៏មានព្រះបន្ទូលសួរថា អាជ័យ អញអោយអាឯងទៅនៅឯទន្លេ អោយរកស៊ីធ្វើស្រែយកស្រូវ ឥលូវនេះអាឯងទៅធ្វើដូច្នេះ តើអាឯងគិតដូចម្តេច បើដូច្នេះឯងថាមកអញនឹងស្តាប់ ទើបធនញ្ជ័យថា ពុំចេះនឹងទ្រង់ព្រះមេត្តាអស់សេចក្តីទាំងនេះ ខ្ញុំទូលព្រះបង្គំជាខ្ញុំគិតឃើញថា កើតជានគរមានស្តេចសោយរាជ្យហើយ អោយចងជាច្បាប់ប្រាប់អស់នាម៉ឺននូវពលអោយបានដឹង នេះឯងជាពន្ធព្រះរាជទ្រព្យអោយបានដឹងថា ច្បាប់ជំនុំសេចក្តីស្រដីគ្រប់មុខ អោយនាម៉ឺនធំតូចដឹងជាសណ្តាប់ប្រាប់អស់រាស្ត្រនៅស្រុកក្រៅ អោយចិញ្ចឹមចៅហ្វាយស្រុក ស្នងក្រឡាពាស ជំទប់ ចៅមឿង មេស្រុក ទើបអោយបានដឹងអំពីខែត្រចៅហ្វាយស្រុកតូចស័ក្តិយស ខ្ពងពោះនាម៉ឺនក្នុង ខ្ពងពោះចៅហ្វាយស្រុកនៅក្រៅអោយមានជាសណ្តាប់ ប្រាប់ឈ្មោះចៅហ្វាយស្រុកមានជាដូច្នោះឈ្មោះខេត្តដូច្នោះ រួចធនញ្ជ័យក្រាបទូលថា ខ្ញុំទូលបង្គំនឹងចង់បានទ្រព្យខ្លួនក៏ទេ ធ្វើដូច្នេះបានជាអាករសួយរៃក្នុងព្រះនគរដាក់ជាព្រះរាជទ្រព្យបានដឹងតរៀងទៅ ។

ស្តេចព្រះមហាក្សត្រាធិរាជទ្រង់ស្តាប់ធនញ្ជ័យក្រាបទូលដូច្នេះហើយ ស្តេចមានព្រះបន្ទូលថា អាឯងថាដូច្នេះត្រូវហើយ តែដែលអាលក់រាស្ត្រនោះធ្ងន់ណាស់ អាយកតែបាទ១វិញ ។

ឯធនញ្ជ័យក៏បានទទួលព្រះបន្ទូលហើយក្រាបលាទៅយកបាទ១ អំពីលោកសង្ឃ ហើយទៅប្រាប់អស់មនុស្សដែលចាប់លក់អំពីមុនថា ត្បិតហ្លួង





មិនអោយយកប្រាក់តម្លឹង៣០ទេ វាធ្ងន់ណាស់អោយអញយកបាត្រ១ អំពីអស់ឯងវិញ ប្រាប់ហើយយកបាត្រមកវាល់ ឯអស់រាស្ត្រខ្លះនឹងយកប្រាក់មកវាល់អោយពេញបាត្រនោះមិនបាន ធនញ្ជ័យក៏ប្រឹងទារ ឯអស់រាស្ត្រនោះរត់ទៅក្រាបទូលថា ពុំចេរនឹងទ្រង់មេត្តា ត្បិតធនញ្ជ័យថាម្ចាស់មិនអោយយកប្រាក់តម្លឹង៣០អោយយកបាទ១ ឥលូវគាត់យកបាត្រលោកសង្ឃមកវាល់វិញ ដូច្នេះឃើញថាធ្ងន់ណាស់ យើងខ្ញុំនឹងរកប្រាក់អោយពេញបាត្រនោះមិនបានទេ ស្តេចមហាក្សត្រស្តាប់ហើយ ក៏ត្រាស់ប្រើអោយហៅអាជ័យមកអោយឆាប់ ឯអាមាត្យលឺព្រះបន្ទូលប្រាប់ដូច្នោះហើយ ក៏ក្រាបថ្វាយបង្គំលាទៅហៅធនញ្ជ័យមកហើយ មានព្រះបន្ទូលសួរថា អាជ័យអាថាអញអោយយកបាត្រទៅយកប្រាក់អំពីរាស្ត្រអង្កាល់ ឯធនញ្ជ័យក្រាបទូលថា ម្ចាស់មានព្រះបន្ទូលថាអោយ១បាទវិញ កុំអោយយក៣០តម្លឹងឡើយ បានជាខ្ញុំព្រះបង្គំយកតាមព្រះបន្ទូលវិសេសនោះ ឯមហាក្សត្រស្តាប់ហើយក៏មានព្រះបន្ទូលថា អញអោយយក៤ស្លឹងប្រាក់ចាយសព្វថ្ងៃនេះទេ ប៉ុន្តែគេហៅថា១បាទ ឥលូវនេះ អាយកតែ៤ស្លឹងវិញ កុំយកបាត្រទៅវាល់នោះមិនត្រូវទេ។ ហើយស្តេចមានព្រះបន្ទូលថា អាជ័យឯងនេះធ្វើអោយក្តៅទឹកដីអញណាស់ នឹងទុកនៅមិនបាន ទើបស្តេចមានព្រះបន្ទូលហៅនាយពេជ្ឈឃាតយកធនញ្ជ័យទៅសំលាប់ ឯក្នុងទន្លេ ជាបំរាមអោយអស់រាស្ត្រវាឃើញ កុំអោយទិងវា។ ឯអស់ពេជ្ឈឃាតស្តាប់ព្រះបន្ទូលហើយក៏ចាប់ធនញ្ជ័យចងនាំទៅសំលាប់ ដូចព្រះបន្ទូលបង្គាប់នោះហោង ឯអស់ពេជ្ឈឃាតនាំធនញ្ជ័យទៅដល់ទូកហើយ អោយយកទូក១មករកគ្នាដាក់អង្គុយអុំគ្រប់ចំនុះទូកពេញហើយ ដាក់ធនញ្ជ័យចំកណ្តាលហើយតាំងហោប៊ីដង ចេញទូកទៅ ធនញ្ជ័យគិតក្នុងចិត្តថា អញនឹងបញ្ឆោតអស់ទាំងពេជ្ឈឃាតកុំអោយសំលាប់អញបាន គិតរួចហើយនិយាយថា អស់បងប្អូន ឥលូវនេះ អញសំលាប់ហើយអញនឹងលេងអោយអស់បងប្អូនសប្បាយម្តងកុំខ្លាច បើរត់តើនឹងទៅឯណានៅក្នុងទឹកនោះឯង ឯអស់ពេជ្ឈឃាតស្តាប់ពាក្យធនញ្ជ័យហើយគិតថា តើនឹងមានបើនឹងរត់ តើដូចម្តេចក៏នឹងរួចក្នុងតែអញនឹងចាប់បាន គិតដូច្នោះហើយក៏ស្រាយធ្នញ្ជ័យចេញ ឯធនញ្ជ័យក៏ថាអោយខ្ញុំទៅកន្សៀទូក ហើយខ្ញុំ

និងច្រៀងបន្ទរលេងអោយសប្បាយ ឯអស់ពេជ្ឈឃាតក៏ព្រមអោយធនញ្ជ័យទៅអង្គុយឯកន្សែច្រៀងបន្ទរថា បើអញថាធនញ្ជ័យធ្លាក់ទឹក ឯងថាហៃអើៗ ឯអស់អ្នកអុំទូកក៏ព្រមថាហៃអើៗ លុះថាតែដូច្នោះរឿយៗទៅហើយ វាពុំបានជាគិតថា ធនញ្ជ័យនឹងលោតទឹករត់ដូច្នោះគិតតែសប្បាយក៏ថាទៅ នឹងដឹងថាដូច្នោះក៏ទេ ។ ឯធនញ្ជ័យថាអោយស្រែកអោយខ្លាំងជាងពីដើមទៀត លុះល្មមតែនឹងលោតទឹកហើយ ធនញ្ជ័យក៏លោតទៅក្នុងទឹកប្រុងទៅ ។

ឯអ្នកកន្សែស្រែកថា ធនញ្ជ័យធ្លាក់ទឹកទៅហើយ អ្នកក្បាលថាហៃអើៗដូចអំពីដើមនោះឯង ឯធនញ្ជ័យក៏ប្រឹងហែលទៅដល់ត្រើយ ហើយដើររស្បង់ចីពរបាន ហើយចូលទៅជួបនឹងលោកសង្ក្រាជនៅក្នុងកុដិលោកនោះ ជាសុខសប្បាយដូចសព្វដងរៀងមក ឯអស់អ្នកអុំទូកនោះលុះបន្តិចដឹងថា ធនញ្ជ័យលោតទឹកទៅ ហើយក៏បន្ទោសគ្នាថា អញមិនដឹងទេ សេចក្តីនេះតាមតែលោកនាយចុះ ខុសត្រូវយើងមិនបានស្រាយធនញ្ជ័យទេ ជជែកគ្នាហើយវិលមកវិញ ហើយឡើងទៅក្រាបទូលថា សូមទានក្រាបទូល ត្បិតទ្រង់បង្គាប់អោយនាំធ្នញ្ជ័យទៅសំលាប់នោះ ធនញ្ជ័យក៏ខឹងចិត្តលោតទឹកទាំងចំនងលិចបាត់ទៅ មិនឃើញអណ្តែតឡើងឡើយ ។ ឯព្រះមហាក្សត្រស្តាប់ហើយ មានព្រះបន្ទូលថា វាហើយទៅចុះ កុំអោយតែវារស់ឡើងវិញ មានព្រះបន្ទូលដូច្នោះហើយ គង់កំសាន្តព្រះទ័យជាសប្បាយឥតមានខ្វាល់ឡើយ ។

លុះដល់យូរបន្តិចទៅ ដឹងលឺដល់ស្រុកចិតថា នៅស្រុកគោកធ្លក ជាស្រុកខ្មែរមានអ្នកប្រាជ្ញមួយឈ្មោះធនញ្ជ័យ ឥតមានអ្នកប្រាជ្ញឯណានឹងស្មើប្រាជ្ញថៅធនញ្ជ័យនោះបាន ប៉ុន្តែឥលូវនេះ គេសំលាប់ទៅហើយ បើដូច្នោះឃើញថា នឹងយកនគរងាយ ស្តេចស្រុកចិនគិតឃើញដូច្នោះហើយ អោយហៅនាម៉ឺនធំតូចមកដល់ហើយ ស្តេចអោយជំនុំរឿងនឹងចាប់យកនគរខ្មែរ ត្បិតស្តេចនគរខ្មែរសំលាប់អ្នកប្រាជ្ញទៅហើយ បើនាម៉ឺនជំនុំគិតគ្នាឃើញ



ដូចម្តេច អោយមកប្រាប់អញ ។ ឯអស់នាម៉ឺនបានស្តាប់ព្រះបន្ទូលហើយមកជំនុំគ្នាថា បើគេសំលាប់អ្នកប្រាជ្ញនោះវាជាហើយ យើងអោយអ្នកប្រាជ្ញយើងទៅចោទប្រស្នា បើរកមិនឃើញ យើងយកនគរនោះបានងាយ គិតឃើញដូច្នោះហើយ ឡើងទៅក្រាបទូលអោយទ្រង់ជ្រាប ថាអស់យើងខ្ញុំគិតទៅឃើញថា អោយអាចារ្យយើងបាន៤នាក់ ទៅចោទប្រស្នាភ្នាល់យកនគរនេះឃើញថាងាយ ត្បិតអ្នកប្រាជ្ញស្រុកខ្មែរស្លាប់ទៅហើយ ស្តេចស្តាប់ហើយក៏ព្រមតាមនាម៉ឺនទូលនោះ ហើយអោយយកអាចារ្យ៤នាក់មក មកដល់ហើយទ្រង់ផ្តាំថា អោយទៅចោទប្រស្នាភ្នាល់នឹងស្តេចស្រុកខ្មែរ បើអ្នកណាចាញ់យកនគរជាចំនុះ ផ្តាំរួចហើយអោយយកសំពៅបាន៤អោយ១ម្នាក់គ្រប់អាចារ្យទាំង៤ ហើយធ្វើព្រះបន្ទូលមកស្រុកខ្មែរអោយបានជ្រាប ឯសេចក្តីក្នុងសំបុត្រព្រះបន្ទូលនោះថា ព្រះរាជសារមេត្រីអំពីស្តេចក្រុងចិន ថ្វាយមកស្តេចស្រុកខ្មែរសូមបានជ្រាប ត្បិតលឺដំនឹងដោយរាស្ត្រទៅរកស៊ីស្រុកខ្មែរថា ស្រុកខ្មែរមានអ្នកប្រាជ្ញ១ ឈ្មោះធនញ្ជ័យជាអ្នកប្រាជ្ញធំ ឥលូវនេះយើងប្រើអ្នកប្រាជ្ញស្រុកយើងអោយមកចោទអាថ៌ប្រស្នាភ្នាល់គ្នា បើអ្នកប្រាជ្ញនគរណាចាញ់ នឹងយកនគរនោះឯង ថ្វាយមកសួរ គួរពុំគួរតាមព្រះទ័យ សេចក្តីអស់តែប៉ុណ្ណោះឯង ធ្វើព្រះបន្ទូលហើយដាក់ក្នុងបំពង់អោយទៅអាចារ្យទាំង៤ ចុះសំពៅបើកដល់ស្រុកខ្មែរ ហើយចតនៅប្របកំពង់ហើយឡើងយកសំបុត្រទៅថ្វាយស្តេចនគរគោកធ្លក ហើយវិលមកនគរវិញ ឯមហាក្សត្រខ្មែរឃើញសំបុត្រព្រះរាជសារ អោយបើកមើលឃើញក្នុងសេចក្តីសព្វគ្រប់ ដូចយើងបានស្រដីអំពីមុន ។ ឯព្រះមហាក្សត្រទ្រង់ជ្រាបគ្រប់ប្រការហើយ គិតស្តាយធនញ្ជ័យថា បើអញមិនអោយសំលាប់វាយល់ជាមិនពិបាកចិត្តទេ ។

យើងនឹងស្រដីអំពីកាលធនញ្ជ័យទៅបួសយូរបានខែ ឯលោកសង្ឃឈ្មោះធនញ្ជ័យនោះគិតថា អញនឹងទៅយកចង្ហាន់បិណ្ឌបាតកងព្រះរាជវាំង

អោយជួបនឹងស្តេច ចង់ដឹងមើលបើឃើញអញ តើស្គាល់រឺទេ លោកជ័យគិតដូច្នោះហើយ ក៏ឃ្លុំចីពរយកបាត្រមកស្ពាយ ដើរចូលទៅក្នុងព្រះបរមរាជវាំងជាមួយនឹងលោកសង្ឃជាច្រើន ឯលោកជ័យនៅក្រោយគេបង្អស់ ព្រះមហាក្សត្រចេញមកដាក់បាតលោកដូចសព្វដងគ្រប់អង្គ នៅតែលោកតាជ័យក្រោយគេបង្អស់ ស្តេចទតទៅឃើញ ស្តេចមានព្រះបន្ទូលថា អញមើលមុខលោកនេះដូចជាមុខលោកជ័យ ឯលោកជ័យថា ជ័យហើយថាមិនជ័យ រួចដើរហួសទៅ ឯព្រះមហាក្សត្រស្ងៀមនៅ ។

លុះដល់ មានសារមកពីស្រុកចិនអោយចោទប្រស្នានោះ ស្តេចគិតថាកាលអំពីមុនអញឃើញលោកសង្ឃមកយកបាត្រប្រហែលអាជ័យក្រែងវាមិនស្លាប់ទេ ហើយវាទៅបួស បើដូច្នោះអញអោយអាមាត្យដើររកដោយវត្តលោកសង្ឃបួសមែន ហើយស្តេចបង្គាប់អោយអាមាត្យ៤នាក់ ថាអស់អាឯងទៅរកអាជ័យក្រែងវារត់ទៅបួស ឯអាមាត្យស្តាប់ហើយក៏ក្រាបថ្វាយបង្គំលាដើរទៅរកធនញ្ជ័យ នៅវត្តលោកសង្ឃ ទៅឃើញនៅវត្តបួសជាសង្ឃហើយអាមាត្យទូលព្រះពុទ្ធដីកាថា ត្បិតមានព្រះបន្ទូលពិសេសអោយនិមន្តលោកទៅ លោកតាជ័យស្តាប់ហើយក៏និមន្តទៅតាមអាមាត្យ លុះទៅដល់ហើយក៏គង់ស្ងៀម ឯព្រះមហាក្សត្រទតទៅឃើញធនញ្ជ័យក៏ត្រេកអរហើយសួរថា លោកតាជ័យអន់ចិត្តនឹងព្រះករុណារឺដូចម្តេច ឯលោកតាជ័យថ្វាយព្រះពរថាទេ ទើបមានព្រះបន្ទូលថា ត្បិតមានអាចារ្យពីស្រុកចិន គេអោយមកចោទប្រស្នាយកនគរ បើដូច្នោះ តើជាលោកដោះរួចរឺទេ ឯលោកតាជ័យថា ដោះថ្វាយកុំព្រួយព្រះហឫទ័យ ស្តេចស្តាប់ហើយក៏ត្រេកអរក្នុងព្រះទ័យ ទ្រង់មានព្រះបន្ទូលនឹងលោកតាជ័យថា បើដូច្នោះ មានតែសឹកចេញ ទើបជា ទើបលោកតាជ័យថ្វាយព្រះពរថា អាត្មាភាពសឹកថ្ងៃនេះឯងកុំព្រួយព្រះហឫទ័យឡើយ ហើយស្តេចអោយសំពត់អាវក្រមាក្រវាត់ ។



លោកតាជ័យទទួលយកសំពត់អំពីព្រះមហាក្សត្រ ហើយលាវិលទៅសឹកចេញ ស្លៀកសំពត់អាវក្រវាត់ក្រមា ហើយក៏ចូលទៅថ្វាយគាល់ ស្តេចទតឃើញហើយស្តេចមានព្រះបន្ទូលថា បណ្ឌិតជ័យគេមកហើយ មើលទៅល្អសមជាបណ្ឌិតអ្នកប្រាជ្ញបានជា បើអ្នកឯណាបួសហើយសឹកចេញគេហៅថាបណ្ឌិតៗ ដូច្នេះឯងរួចហើយស្តេចដណ្តឹងថា ឥលូវនេះនឹងអោយអាចារ្យចិនគេឡើងមកចោទប្រស្នាថ្ងៃណា ទើបបណ្ឌិតជ័យក្រាបទូលថា ក្នុងបីថ្ងៃទៀតអោយឡើងមកនិងចោទប្រស្នាគ្នា ហើយបណ្ឌិតជ័យអោយគេរកគម្ពីរអោយច្រើន ហើយអោយរកមហាតលិកបាន៤នាក់ អោយយកខ្មៅដុសអោយបានច្រើនដាក់នឹងថាសនោះ៤ ហើយអោយយកក្តារធំរលីង៤ជ្រុងមកអោយហើយអោយចាប់ក្តាមអោយបាន៤ ក្អមហើយអោយយកគ្រដាសសពុម្ពធំអោយច្រើនមកអោយ ទូលព្រះបង្គំនឹងធ្វើប្រស្នាថ្វាយ កុំព្រួយព្រះរាជហឫទ័យ ឯព្រះមហាក្សត្រស្តាប់ហើយអោយរកតាមពាក្យធនញ្ជ័យបង្គាប់បានមកហើយអោយយកទៅប្រគល់អោយធនញ្ជ័យ រួចហើយអោយបំរើទៅប្រាប់អាចារ្យស្រុកចិនដែលមកចតសំពៅនៅកំពង់ នៅមុខព្រះលាន មានព្រះបន្ទូលអោយប្រាប់មកថា បីថ្ងៃទៀតឡើងទៅចោទប្រស្នានឹងអ្នកប្រាជ្ញយើងស្រុកខ្មែរចុះកុំខានឡើយ ឯអាចារ្យស្រុកចិនស្តាប់ហើយទទួលតាម លុះដល់ថ្ងៃត្រូវសន្មតហើយអាចារ្យចិនឡើងចោទប្រស្នា ឯធនញ្ជ័យក៏ដើរចុះទៅទទួលពាក់កណ្តាលផ្លូវ មុខព្រះលានស្តេចនោះឯង អាចារ្យស្រុកចិនមើលទៅឃើញធនញ្ជ័យដើរមកអំពីចំងាយហើយធ្វើប្រស្នា ចង្អុលទៅមើល ឯធនញ្ជ័យចង្អុលទៅព្រះអាទិត្យ អ្នកប្រាជ្ញចិនចង្អុលទៅក្រៅដី លាបាតដៃហើយលើកម្រាមដៃបញ្ឈរឡើងទៅលើ អ្នកប្រាជ្ញចង្អុលចុះទៅក្រោមធនញ្ជ័យចង្អុលមកខ្លួនឯង ។

ឯអ្នកប្រាជ្ញស្រុកចិនសួរថា កាលយើងចង្អុលទៅលើមេឃ ហើយអ្នក





ឯងចង្អុលទៅព្រះអាទិត្យនោះ តើអ្នកឯងដឹងដូចម្ដេច ទើបធនញ្ជ័យថាអញដឹងថា អ្នកឯងចង្អុលទៅលើមេឃនោះ គឺអ្នកឯងសួរថាមានសត្វអ្វី ឯអញចង្អុលទៅព្រះអាទិត្យនោះ តើអ្នកឯងដឹងរឺទេ អ្នកប្រាជ្ញចិនថាអញដឹង អ្នកឯងថាមេឃនោះមានតែព្រះអាទិត្យព្រះច័ន្ទនោះឯងនៅលើមេឃ ទើបអ្នកប្រាជ្ញស្រុកចិនថា ដែលអញចង្អុលទៅក្រៅដីនោះ តើអ្នកឯងថាដូចម្ដេច ទើបធនញ្ជ័យឆ្លើយថាអញដឹងហើយ ឯចង្អុលទៅខាងក្រៅនោះថា សត្វអ្វី ទើបធនញ្ជ័យថាអញធ្វើម្រាមដៃឡើងទៅលើជុំវិញនោះ តើអ្នកឯងថាសត្វអ្វី ទើបអាចារ្យចិនថាអញដឹង បានជាអ្នកឯងធ្វើដូច្នោះ ថាក្រៅផែនដីមានទឹកសមុទ្រ ក្រៅសមុទ្រនោះ មានភ្នំចក្រវាលក្រៅពោះឯង ទើបអាចារ្យចិនថា អញចង្អុលចុះក្រោមនោះ តើអ្នកឯងដឹងរឺទេ ធនញ្ជ័យថាអញដឹង ឯងចង្អុលចុះក្រោមនោះថា នៅលើដីនេះ តើមានសត្វអ្វី ធនញ្ជ័យថាអញចង្អុលមកខ្លួនអញនោះ តើឯងដឹងរឺទេ ឯអាចារ្យចិនថាអញដឹង ឯងចង្អុលខ្លួនឯងនោះថា នៅដីនេះមានតែមនុស្ស ។ សួរឆ្លើយទទួលគ្នា រួចហើយអាចារ្យចិនលាធនញ្ជ័យវិលទៅសំពៅវិញ ។

លុះព្រឹកឡើងមកជួបនឹងធនញ្ជ័យ ឯអាចារ្យចិនធ្វើប្រស្នាអោយធនញ្ជ័យ ចាប់ធ្វើជារង្វង់ ឯធនញ្ជ័យធ្វើបត់ជុំដៃបង្ហាញទៅ អាចារ្យលាម្រាមដៃទាំង៥ បង្ហាញមកធនញ្ជ័យ ធនញ្ជ័យបង្ហាញម្រាម១ បង្ហាញទៅអាចារ្យចិន អាចារ្យចិនឃើញហើយវិលទៅសំពៅវិញ ឯធនញ្ជ័យក៏វិលទៅផ្ទះវិញ ។

លោកគ្រូសង្ក្រាជបានលឺធនញ្ជ័យចោទប្រស្នានឹងអាចារ្យចិនដូច្នោះហើយ ក៏និមន្តមកសួរចង់ដឹងដំនើរនោះ ជួបនឹងធនញ្ជ័យហើយដណ្ដឹងថា កាលអ្នកចោទប្រស្នានឹងចិនធ្វើដូចម្ដេច ទើបធនញ្ជ័យទូលថា ចិនធ្វើដៃជារង្វង់ ខ្ញុំបង្ហាញជុំដៃ ចិនលាដៃបង្ហាញម្រាមទាំង៥ ខ្ញុំក្ដាប់បង្ហាញម្រាមដៃ១ ។

ទើបលោកគ្រូសង្ក្រាជដណ្ដឹងថា បើដូច្នោះ តើដូចម្ដេច ទើបធនញ្ជ័យថា ឯចិនធ្វើដៃជារង្វង់ដូច្នោះខ្ញុំថាធ្វើអង្រុតរុតត្រី ទើបខ្ញុំបង្ហាញកែងដៃនោះថាបើអង្រុតរុតត្រីដូច្នោះ តើរុតបានត្រីប៉ុន្មាន ឯបង្ហាញម្រាមដៃប្រាំនោះ ថា

បើបានត្រីប៉ុណ្ណោះ ល្មមធ្វើងៀតបាន៥ចំរៀក ឯបង្ហាញចង្អុលដៃ១ថាស៊ី ១ថ្ងៃ១ចំរៀក ក្នុងត្រី១ កន្ទុយបាន៥ថ្ងៃទើបអស់ ។ លោកគ្រូសង្រ្គាជបានដឹងហើយវិលទៅកុដិវិញ ។

ទើបលោកសម្តេចចៅហ្វាយទៅសួរធនញ្ជ័យ ចង់ដឹងអំពីប្រស្នាចិននោះ ថាដូចម្តេចប្រាប់អញផងអញចង់ដឹង ធនញ្ជ័យស្តាប់ហើយជំរាបថា ចិនធ្វើដៃជារង្វង់ ខ្ញុំបង្ហាញកែងដៃ ចិនបង្ហាញម្រាម៥ ខ្ញុំបង្ហាញចង្អុលដៃ១ លោកសម្តេចចៅហ្វាយដណ្តឹងថា បើដូច្នោះ ថាដូចម្តេច ធនញ្ជ័យប្រាប់ថា ចិនឱបដៃជារង្វង់នោះថានឹងចាប់យកនគរ ។ ខ្ញុំបង្ហាញជុំដៃថា អញថងនឹងកែងដៃ ចិនបង្ហាញម្រាម៥ ថាគេមានគ្នាច្រើន ខ្ញុំបង្ហាញចង្អុលដៃ១នោះថា អញតែម្នាក់ឯង អញវាយឯងមិនខ្លាចទេ លោកចៅហ្វាយលឺដូច្នោះហើយក៏វិលទៅវិញ ឯព្រះមហាក្សត្រស្តេចអោយហៅធនញ្ជ័យសួរថា កាលអាចារ្យចិនគេចោទថាដូចម្តេចខ្លះ ធនញ្ជ័យក្រាបទូលថា កាលអាចារ្យចិនគេមកដល់ធ្វើដៃជាឱបដៃ បង្ហាញទូលព្រះបង្គំបត់កែងដៃបញ្ឈរបង្ហាញទៅវិញ ហើយអាចារ្យចិនបង្ហាញម្រាមដៃទាំង៥ ទូលព្រះបង្គំបង្ហាញម្រាមដៃ១ទៅវិញ ទើបស្តេចមានព្រះបន្ទូលដណ្តឹងថា ដូចម្តេចបើដូច្នោះ ទើបធនញ្ជ័យក្រាបទូលថា ឯចិនឱបដៃបង្ហាញមកសួរថា ក្នុងទ្វីបទាំង៤នេះ តើមានអ្វីខ្លះ ទូលព្រះបង្គំបត់ជុំដៃបង្ហាញនោះប្រាប់ថា មានព្រះសិនេរុត្រង់កណ្តាល ទើបចិនបង្ហាញម្រាមទាំងប្រាំនោះដណ្តឹងថា មានព្រះពុទ្ធ៥ព្រះអង្គបានត្រាស់ក្នុងកប្បនេះ ទើបទូលបង្គំបង្ហាញម្រាមដៃ១ នោះប្រាប់ថា ៥អង្គប៉ុន្តែបានត្រាស់៤អង្គទៅហើយ នៅតែ១អង្គទៀត មិនទាន់បានត្រាស់នៅឡើយ ប្រស្នានេះដូច្នេះឯង សូមទ្រង់ជ្រាប ហើយធនញ្ជ័យថ្វាយបង្គំលាទៅផ្ទះវិញ ។

លោកគ្រូសង្រ្គាជ និងសម្តេចចៅហ្វាយទៅជួបនឹងមហាក្សត្រ ហើយ



និយាយតាមដំនើរដែលបានដណ្តឹងធនញ្ជ័យ កាលចោទប្រស្នានឹងចិនក្រាបទូលស្តេចៗស្តាប់ហើយមានព្រះបន្ទូលថា វាប្រាប់លោកគ្រូសង្រ្គាជផ្សេង ប្រាប់ចៅហ្វាយផ្សេង វាប្រាប់អញផ្សេង នឹងអោយប្រាកដជាប្រស្នាដូចម្តេចនោះមិនបានឡើយស្តេចនូវអស់ទាំងនាម៉ឺនខ្លាចប្រាជ្ញាធនញ្ជ័យណាស់ ។

ឯធនញ្ជ័យក៏វិលទៅផ្ទះ ហើយអោយយកខ្មៅដុសក្តារ៤ជ្រុងក្រដាស និងគម្ពីរដែលអោយគេរកហើយនិងក្តាមដែលដាក់ក្នុងក្អមទាំង៤នោះមក ហើយក៏យកក្តាមដាក់ត្រង់កណ្តាល ហើយយកថាសដាក់ទឹកខ្មៅ ដាក់គ្រប់ជ្រុងទាំង៤ ហើយយកក្រដាសក្រាលលើក្តារ ហើយយកក្តាមដាក់ក្នុងថាសទឹកខ្មៅអោយវាវារឡើងលើក្រដាសនោះ ឯទឹកខ្មៅដែលប្រឡាក់នូវជើងក្តាវារនោះជិតជាប់និងក្រដាសនោះច្រើន ហើយយកទៅហាលថ្ងៃលុះធ្វើដូច្នេះឯងបានច្រើនហើយ អោយយកគម្ពីរមករុំទុក ហើយយកក្រដាសមកដាក់អោយក្តាមវាវារលើជាច្រើនទៀត រួចហើយអោយយកក្តារនិងទឹកខ្មៅទៅទុក ទើបអោយកូនក្មេងមកអង្គុយច្រើន ហើយយកក្រដាស១ពុម្ពម្នាក់ៗអោយក្មេងអស់នោះទន្ទេញថាផ្តេសផ្តាសទៅតាម តែក្មេងណាចង់ថាដូចម្តេចក៏ថាទៅ អោយលឺដូចក្មេងរៀនអក្សរសាស្ត្រ ឯអ្នកប្រាជ្ញចិននោះលុះដល់ព្រឹកឡើងហើយ ឡើងពីសំពៅមកផ្ទះធនញ្ជ័យ នឹងចោទប្រស្នា ឯធនញ្ជ័យមើលទៅឃើញអាចារ្យមកដល់ហើយ ក៏ដើរទៅទទួលចាប់ដៃចូលមកអង្គុយលើកៅអី ហើយធនញ្ជ័យអោយយកទឹកតែមកអោយអាចារ្យផឹក ឯក្មេងទាំងនោះក៏រៀនអក្សរលឺកងរំពងនឹងស្តាប់ភាសាគ្នាមិនបានឯអាចារ្យចិនឃើញអស់ក្មេងរៀនសំបុត្រហើយអោយយកទៅបកមើលមិនស្គាល់តួអក្សរដល់១សោះ ឯធនញ្ជ័យសួរថា អាចារ្យស្គាល់អក្សរនេះរឺទេ អាចារ្យចិនថាទេ ទើបធនញ្ជ័យថា នេះគេហៅអក្សរមីងឆ្មេង អក្សរព្រាហ្មណ៍ចាមបើមិនស្គាល់ដូច្នេះនឹងឆ្លើយប្រស្នានឹងគ្នាមិនបានទេ អ្នកឯងចាញ់អញនឹង

អក្សរនេះហើយ អាចារ្យចិនក៏ទទួលព្រម ធនញ្ជ័យថា បើចាញ់ហើយអញយកតែរបស់ក្នុងសំពៅទាំង៤ឯសំពៅនោះ អញអោយវិលត្រលប់ទៅស្រុកវិញ ឯនគរក៏អញថ្វាយទៅស្តេចក្រុងចិនវិញដែរ តែអំពីថ្ងៃនេះ បើលឺឈ្មោះធនញ្ជ័យ អ្នកប្រាជ្ញអោយខ្លាចគ្រប់ប្រទេសទៅ អាចារ្យចិនក៏ព្រមអោយរបស់ក្នុងសំពៅទាំង៤នោះ ហើយក៏បើកសំពៅទៅស្រុកវិញ ឯធនញ្ជ័យកាលបើបានរបស់អំពីសំពៅទាំង៤នោះហើយ អោយជញ្ជូនអស់របស់ទ្រព្យនោះទៅថ្វាយព្រះបាទជាម្ចាស់ទាំងអស់ នឹងមានយកជារបស់ខ្លួនក៏ទេ ឯព្រះមហាក្សត្រ បានលឺថាធនញ្ជ័យឈ្នះប្រស្នាអាចារ្យចិនដូច្នោះហើយ លុះដល់ឃើញធនញ្ជ័យអោយជញ្ជូនអស់រប់ស់ទ្រព្យមកថ្វាយដូច្នោះក៏ត្រេកអរក្នុងព្រះរាជហឫទ័យ ហើយមានព្រះបន្ទូលថា ធនញ្ជ័យឯងបានទុកខ្លះហើយរឺទេរបស់ទាំងអស់នេះ ធនញ្ជ័យក្រាបទូលថា ទូលព្រះបង្គំពុំបានយកទុកទេស្តេចស្តាប់ហើយក៏មានព្រះបន្ទូលថា បើដូច្នោះអញនឹងអោយយកស្រីក្នុងវាំងធ្វើជាប្រពន្ធឯង ហើយនឹងរបស់ទ្រព្យទាំងអស់គ្រប់មុខកុំអោយមានខ្វះខាតរបស់អ្វី ឯធនញ្ជ័យក្រាបទូលថា ទូលបង្គំមិនចង់បានទេ ប្រពន្ធនោះ ត្បិតមិនមែនជាស្រីទេ ឈ្មោះញី មិនប្រាកដជាស្រី សូមជ្រាប ស្តេចទ្រង់សណ្តាប់ហើយក៏មានព្រះបន្ទូលថា ឯណាឈ្មោះស្រីនោះ ទើបធនញ្ជ័យថា ទូលព្រះបង្គំនឹងក្រាបថ្វាយបង្គំលាទៅរក បើបាននឹងនាំមកថ្វាយ ហើយទូលថា សូមព្រះអង្គព្រះរាជទានសំពត់ហូល ព្រៃ អោយច្រើននឹងទៅរកស្រីនោះទើបឃើញ ស្តេចស្តាប់ហើយ ព្រះរាជទានហូលព្រៃអោយធនញ្ជ័យជាច្រើន ហើយទ្រង់ផ្តាំថា បើរកបានវិលមកឆាប់ ឯធនញ្ជ័យក្រាបទូលថ្វាយបង្គំលា យករបស់នោះវេចស្រេចហើយ ស្ពាយសំពាយដើរទៅស្រីនោះ ។

លុះដល់ទីណាមានគេនៅច្រើននោះ ចូលទៅសួរគេថា ស្រុកនេះមាន



ស្រីរឺទេ អ្នកស្រុកប្រាប់ថាស្រីមានដែរ ទើបធនញ្ជ័យថា មិនមែនស្រីទេ នេះគេហៅថាឈ្មោះញី មិនមែនស្រីទេ ធនញ្ជ័យថាហើយដើរទៅរកភូមិគេឯទៀតវិញ ហើយចូលទៅសួរថា ក្នុងស្រុកនេះ តើមានស្រីរឺទេ អស់អ្នកស្រុកប្រាប់ថា ខ្ញុំឆ្ងល់ណាស់ ចុះអស់ទាំងអស់ស្រីនេះ តើគេហៅថាជាអ្វីវិញ ឯធនញ្ជ័យថា ទេ នេះគេហៅញីទេថាហើយក៏ដើរទៅសួររកស្រីឯទៀត លុះទៅដល់ភូមិផ្ទះនាងសួស្តី ហើយដើរទៅសួររកស្រី ក៏ប្រទះនឹងនាងសួស្តីមកអង្គុយនៅដីមុខផ្ទះនោះឯង ឯធនញ្ជ័យចូលទៅដល់ហើយក៏ដណ្តឹងសួរថា អ្នកប្អូននៅទីនេះមានស្រីទេ ឯនាងសួស្តីស្តាប់ហើយឆ្លើយថា អ្នកឯងនេះនៅស្រុកណា មានទេប្រុសក្នុងស្រុកអ្នកឯង ឯធនញ្ជ័យស្តាប់ហើយក៏គិតថា ហើយគេហៅថាស្រីសួស្តី ទើបធនញ្ជ័យប្រាប់ថា ឯស្រុកខ្ញុំមានប្រុសដែរ តើនាងដឹងរឺទេ ឈ្មោះប្រុសនោះឯង នាងសួស្តីថា ខ្ញុំដឹង បានជាគេហៅប្រុសនោះ ត្បិតគេឈ្មោះជ័យនោះឯង ជ័យនោះច្រើនជាធំជាងអស់ឈ្មោះផង ជ័យឈ្នះអស់ក្នុងផែនដីនេះ ឯងបានជាហៅប្រុសៗ ត្បិតឈ្មោះជ័យនោះឯង ទើបនាងសួស្តីថា អ្នកឯងស្គាល់ទេស្រីនោះ ទើបធនញ្ជ័យថា ខ្ញុំស្គាល់ បានជាគេហៅស្រីៗនោះត្បិតតែឈ្មោះសួស្តីនោះឯង ជាសួស្តីមង្គលជាធំ ក្នុងផែនដីនេះ នឹងយកឈ្នះណាអោយដូចគ្មាន បានជាគេហៅស្រីៗនោះ ត្បិតតែឈ្មោះសួស្តី ទើបធនញ្ជ័យសួរថា នាងមានខ្លាច រឺគ្មានខ្លាចទេ នាងសួស្តីឆ្លើយថា ខ្ញុំគ្មានខ្លាចទេ ថាអ្នកឯងតើមានក្រែង រឺមិនក្រែងទេ ធនញ្ជ័យឆ្លើយថា ខ្ញុំគ្មានក្រែងអ្វីទេ ហើយធនញ្ជ័យដណ្តឹងថា ខ្ញុំសួរនាងថាខ្លាចគ្មានខ្លាចនោះ តើនាងដឹងរឺទេ នាងសួស្តីឆ្លើយថា ខ្ញុំដឹងហើយ គឺអ្នកដណ្តឹងថា មានប្តីរឺនៅឡើយ បើមានប្តីហើយខ្លាចប្តីដេរបើគ្មានប្តីទេនោះថាមិនខ្លាចទេ ទើបនាងសួស្តីដណ្តឹងថា ក្រែងរឺមិនក្រែង នោះតើអ្នកថាដូចម្តេច ទើបធនញ្ជ័យប្រាប់ថា ខ្ញុំដឹង នាងឯងសួរខ្ញុំថា មានប្រពន្ធហើយរឺនៅ





ទេ បើមានប្រពន្ធហើយក្រែងចិត្តប្រពន្ធនោះ បើគ្មានប្រពន្ធទេ ថាមិនក្រែងចិត្តនរណាទេ ឯធនញ្ជ័យបានដឹងថានាងសួស្ដីគ្មានប្ដីដូច្នេះហើយក៏ដាក់សំពាយអំពីស្មា ហើយស្រាយសំពាយហួលចេញអោយម្ដាយឪពុកនាងសួស្ដីឃើញ ។

ឯម្ដាយឪពុកនាងសួស្ដីឃើញហួលព្រែធនញ្ជ័យ ក៏ដើរមកមើលហើយសួរថា អ្នកកូននឹងយកទៅណា ឯធនញ្ជ័យសំពះជំរាបសួរថា ខ្ញុំយកមករកប្រពន្ធទេ បើលោកម្ដាយលោកឪពុកមេត្តាខ្ញុំ ខ្ញុំនឹងនៅបំរើជាកូនក្នុងផ្ទះដងទឹក កាប់អុស បុកស្រូវ ខ្ញុំចេះតែព្រម មិនខ្ជិលច្រអូសឡើយ ឯម្ដាយឪពុកនាងសួស្ដី និងខ្លួននាងសួស្ដីក៏ឡើងលើផ្ទះ ហើយប្ដី និងប្រពន្ធនិយាយគ្នាថា ចៅកំលោះនេះចង់បានកូនយើងហើយ គិតតែពីរនាក់ថា បើដោយស្មានមើលទៅឃើញជាកូនគេអ្នកបានណាស់ មានទាំងហួលព្រែនោះច្រើនយើងល្មមអោយកូនយើងហើយ ឯធនញ្ជ័យកាលបើម្ដាយឪពុកក្មេកឡើងលើផ្ទះហើយ ក៏វេចបង្វិចដើរទៅទីណាកំបាំង ហើយយកក្រដាសមកសរសេរកត់ជាចំណាំឈ្មោះនាម៉ឺនធំតូចដែលជំពាក់ប្រាក់ ខ្លះជំពាក់១០០តម្លឹង ខ្លះជំពាក់៤០០តម្លឹង ខ្លះជំពាក់៥០០តម្លឹង បានច្រើនហើយចង១បាច់ ដាក់ក្នុងសំពាយឡើងទៅលើផ្ទះសំពះម្ដាយឪពុកក្មេក ហើយអង្គុយស្ងៀមចាំស្ដាប់ ។ ម្ដាយឪពុកនាងសួស្ដីក៏ដណ្ដឹងថា អញនឹងចង់សួរចិត្តដឹងឯងៗចង់បានកូនអញមែនរឺទេ ទើបធនញ្ជ័យសំពះហើយជំរាបថា ក្នុងចិត្តខ្ញុំបាទចង់បាន ក្រែងតែលោកមិនអោយទានខ្ញុំបាទ បើលោកមេត្តាជាកូនជាចៅ នោះក៏អរគុណណាស់ និងនៅបំរើអស់ចិត្ត ឯម្ដាយឪពុកនាងសួស្ដី ថាយើងយើងអោយហើយ ចូរឯងទៅរកទិញមាន់ ទា ជ្រូក អណ្ដើក កុំខាន បើមិនបានអណ្ដើកនោះ មេបាយើងមិនទទួលទេ ។

ឯធនញ្ជ័យបានលឺពាក្យម្ដាយឪពុកក្មេកបង្គាប់ដូច្នោះហើយ ក៏ដើរទៅរកអស់អ្នកស្រុកភូមិទាំងនោះ រើសរកតែអ្នកដែលមានប្ដីប្រពន្ធអំពីកំលោះ

ក្រមុំ ទើបយក ហើយអោយឈ្មោះថាមេអណ្តើកទើបរកស្រី៤នាត់ទៀត បើបានច្រើនដល់៨ រឺ១៤នាក់ នោះរឹងរិតតែជាការល្អ អោយតែមានប្តីអំពីក្មេង បើទើបមានកូន១ ក៏បានដែរ អោយឈ្មោះថាកូនអណ្តើក ទើបរកមនុស្សប្រុសម្នាក់ដែលមានយសសក្តិ មានប្រាជ្ញាអោយឈ្មោះជាអ្នកមហាអស់អ្នកប្រុសស្រីទាំងនោះ យកមកដណ្តឹងកូនគេហើយ ធនញ្ជ័យអោយទិញអស់ទំនិញតាមបង្គាប់ម្តាយឪពុកនាងសួស្តី លុះទិញបានសព្វគ្រប់ហើយអោយអ្នកមហានះទៅជូនម្តាយឪពុកខាងស្រីខ្លះ ទុកខ្លះរៀបស្លដណ្តាំធ្វើនំគ្រប់មុខអោយហៅភ្ញៀវមកផឹកសង្កត់រោងរួចហើយ ព្រឹកឡើងបានជ័យល្អហើយ អ្នកមហា និងមេអណ្តើកក៏រៀបអស់បណ្ណាការនូវចិញ្ចៀន ត្រសាល់ទៅបំពាក់កូនស្រីនោះ ហើយអោយខាងស្រីនោះរៀបរោងចាំទទួលអស់អ្នកមហានូវបណ្ណាការនេះ ។ ឯអ្នកមហា មេអណ្តើក និងអស់ក្មេងដែលកាន់គ្រឿងបណ្ណាការដើរទៅដល់ហើយ អ្នកមេបាមកទទួលអ្នកមហាឡើងទៅលើរោង ទើបអ្នកមហាអោយយកស្រា២ដបតម្កល់នឹងជើងពានហើយ ទើបយកថង់មក យកក្មេងអោយកាន់រងថង់ហិប ហើយអ្នកមហាជំរាបថា យើងមកជំរាបអស់លោកមេបាចាស់ទុំសូមជ្រាប ត្បិតយើងបានចិញ្ចៀន និងចារុត្រសាល់ មកសូមបំពាក់កូនស្រី ហើយសូមលើកស្លាដក់ស្លាកន្សែង ជំរាបរួចហើយទើបអស់មេអណ្តើក ចូលទៅបំពាក់ចិញ្ចៀនកូនស្រីនោះរួចហើយទើបខាងស្រីនោះលើកថាសបាយ និងស្រាមកស៊ីផឹក រួចហើយលាគ្នាទៅផ្ទះទីទៃៗហៅថ្ងៃកំនត់ហោង ។

លុះព្រឹកឡើងបានពេលា អ្នកមហា និងមេអណ្តើក កូនអណ្តើកនាំកូនប្រសាឈ្មោះធនញ្ជ័យ ទៅសំពះម្តាយឪពុក ហើយយកកូនស្រីឈ្មោះនាងសួស្តីមកផ្ទឹមនឹងធនញ្ជ័យ ហើយរាងបើកបាយខុនចងដៃរួចហើយ ដល់យប់ផ្សំដំនេក អ្នកជ័យ និងនាងសួស្តីជាប្តីប្រពន្ធ រួចការវល់ពីថ្ងៃនេះទៅ



ហើយទើបធនញ្ជ័យនិយាយនឹងឪពុកក្មេក និងប្រពន្ធថា នឹងទៅទារប្រាក់ដែលអស់នាហ្មឺនជំពាក់ ។

ធនញ្ជ័យទៅដល់សាលាជំនុំអស់នាម៉ឺនធំតូចច្រើន ក៏ឡើងទៅលើសាលា ហើយនិយាយនឹងអស់នាហ្មឺនថា បើចង់ភ្នាល់នឹង ខ្ញុំៗនឹងប្រើស្តេចអោយបាន ទើបអស់នាហ្មឺនថា អើយើងភ្នាល់គ្នា បើឯងប្រើបានអញនឹងអោយប្រាក់ បើឯងប្រើមិនបាន ឯងអោយរបស់អ្វីយើង ធនញ្ជ័យថា ខ្ញុំអោយប្រាក់ ហើយធនញ្ជ័យយកសំបុត្រដែលធ្វើនោះមានឈ្មោះគ្រប់នាម៉ឺនហើយសូមបោះត្រាទទួលជំពាក់រួចហើយ អោយទៅប្រើហ្លួងនឹងមើល ឯធនញ្ជ័យថា បើដូច្នោះអស់លោកទូលថា ត្បិតធនញ្ជ័យវាថា វានឹងប្រើហ្លួងអោយបានដូចចិត្តវាៗថានឹងមកឥលូវនេះហើយ ឯអស់នាម៉ឺនបានស្តាប់ហើយក៏យកសេចក្តីទៅក្រាបទូលហ្លួង ទៅដល់ហើយក្រាបថ្វាយបង្គំគាល់ទូលថា សូមទានត្បិតធនញ្ជ័យវាថា វានឹងមកប្រើអម្ចាស់អោយបានដូចចិត្តវា ឯព្រះមហាក្សត្រស្តាប់ហើយ ក៏ទ្រង់ព្រះក្រោធនឹងធនញ្ជ័យវាមាកងាយហើយត្រាស់ថាទៅហៅអាជ័យមកអោយឆាប់ អាមាត្យស្តាប់ព្រះបន្ទូលត្រាស់ប្រើដូច្នោះ ក៏រត់ទៅហៅធនញ្ជ័យតាមព្រះបន្ទូល ដល់ហើយប្រាប់ធនញ្ជ័យថា ហ្លួងមានព្រះបន្ទូលអោយហៅ ត្បិតទ្រង់ព្រះក្រោធនឹងឯងណាស់ ឯធនញ្ជ័យស្តាប់ហើយក៏ទៅតាមអាមាត្យ ដល់ហើយក៏ក្រាបថ្វាយបង្គំ ស្ងៀមនៅហើយព្រះមហាក្សត្រមានព្រះបន្ទូលសួរថា អាជ័យអាថានឹងមកប្រើអញមែនរឺ ធនញ្ជ័យទូលថាព្រះករុណាវិសេស ប៉ុន្តែនឹងមិនទាន់ប្រើបាន បើបែរព្រះភក្ត្រមើលទៅក្រោយរួចហើយ ទើបប្រើបាន ស្តេចស្តាប់ហើយក៏បែរព្រះភក្ត្រទតមើលទៅក្រោយ ហើយបែរមកវិញ ថាអញមើលទៅហើយអាឯងមិនប្រើចុះ ឯធនញ្ជ័យក្រាបទូលថា នេះហៅប្រើហើយ គឺប្រើអោយបែរទៅក្រោយបានហើយ នឹងមានប្រើអម្ចាស់អោយទៅទូលវែករបស់អ្វីក៏

ទេ ។

ស្តេចស្តាប់ហើយក៏មិនមានព្រះបន្ទូលឡើយ ទ្រង់ស្ងៀម ធនញ្ជ័យក្រាបថ្វាយបង្គំហើយ ទៅទារប្រាក់អំពីអស់នាម៉ឺនដែលភ្នាល់ ហើយមានសំបុត្របោះត្រាយកប្រាក់ច្រើនប្រមាណនឹងមិនរួច ហើយយកទៅអោយប្រពន្ធនូវម្តាយឪពុកក្មេក ហើយនៅជាសុខសប្បាយទៅ ។

ឯអស់នាម៉ឺនដែលធនញ្ជ័យយកប្រាក់នោះកើតខឹងនឹងធនញ្ជ័យទាំងអស់ ទាំងស្តេចក៏ខ្នាល់ណាស់ដែរ ស្តេចអោយហៅអស់នាម៉ឺនធំតូច យុន ហ្មឺន មហាតលិកមកអោយគិតជំនុំ នឹងបំបរបង់ធនញ្ជ័យអោយហើយ ត្បិតវាបង្កើតទោសច្រើនណាស់ ឯអស់នាហ្មឺនស្តាប់ព្រះបន្ទូលដូច្នោះហើយ ក៏មកគិតជំនុំគ្នាឃើញថា នឹងបណ្តេញវាអោយចុះសំពៅទៅស្រុកចិន ត្បិតស្រុកនោះធំហើយគេស្អប់វាតែឃើញវាទៅគេគង់សំលាប់ចោល យើងបានសុខសប្បាយក្នុងនគរ ឯព្រះមហាក្សត្រក៏សប្បាយក្នុងព្រះរាជហឫទ័យ គិតឃើញដូច្នោះហើយ យកសេចក្តីឡើងទៅក្រាបទូលដោយដំនើរដែលបានជំនុំឃើញ ព្រះមហាក្សត្រស្តាប់ហើយក៏ព្រម និងអោយទៅហៅធនញ្ជ័យមកប្រាប់ថា អាជ័យ អញនឹងអោយឯងទៅនៅស្រុកចិននឹងគេឯណោះ ត្បិតស្រុកគេធំ នៅទីស្រុកខ្មែរនេះមិនបានទេ មានព្រះបន្ទូលបង្គាប់អោយយកសំពៅ១មកអោយ ធនញ្ជ័យចុះទៅក្នុងសំពៅ ហើយអោយយកទៅប្រោសចោលឯស្រុកចិន អោយស្តេចក្រុងចិនសំលាប់ កាលធនញ្ជ័យទៅដល់ស្រុកចិនហើយ ផ្តាំអស់អ្នកសំពៅដែលគេវិលមកស្រុកខ្មែរវិញថា អញផ្តាំទៅប្រពន្ធអញផង កុំអោយគិតទុក្ខនឹងអញឡើយ អញនឹងទៅវិញឆាប់ទេ អញសន្មតតែ៧ខែ អោយគេជូនអញទៅវិញឆាប់ទេ កុំថប់ព្រួយចិត្តឡើយ ឯអ្នកសំពៅថា អើសឹមអញប្រាប់អោយបានទេថាហើយក៏ចេញសំពៅមកស្រុកវិញ ។



ឯធនញ្ជ័យក៏ដើរទៅដល់ផ្ទះនាម៉ឺនធំ ចូលទៅស៊ីឈ្នួលអោយគេប្រើធ្វើការ ដើរតាមនាម៉ឺននោះទៅគាល់ស្តេចនោះ ឯនាហ្មឺននោះនឹងបានដឹងថាជាធនញ្ជ័យក៏ទេ ក៏គិតថាខ្មែរតែផ្តាស់មិនបានសួរដណ្តឹងឡើយ ឯធនញ្ជ័យគិតថា បើអញបានប្រាក់ឈ្នួលច្រើន អញនឹងគិតទិញអង្ករ ហើយពិតធ្វើនំរោយនិងប៉ែនអោយមានសរសៃអង្ករឡើងវែងៗ ហើយនិងលក់ទិញស៊ីមិនអោយក្រពិបាកឡើយ គិតហើយធ្វើនំដូចចិត្តគិតនោះឯង ហើយលក់អោយចិនទិញស៊ី កាលនោះស្រុកចិនមិនទាន់ចេះធ្វើនំនេះទេ ដល់ឃើញធនញ្ជ័យធ្វើដូច្នោះហើយ ក៏បបួលគ្នាមកទិញនំស៊ីៗ ហើយនិយាយថាអ្នកនេះធ្វើនំល្អណាស់ លឺទៅដល់ស្តេចក្រុងចិនៗអោយហៅធនញ្ជ័យទៅដល់ហើយមានព្រះបន្ទូលដណ្តឹងថា ឯងធ្វើនំវែងៗមែនរឺ ធ្នញ្ជ័យក្រាបទូលថាមែន ស្តេចមានព្រះបន្ទូលថា អាយកមកអោយអញមើលផង ទើបធនញ្ជ័យវិលមកយកនំនោះទៅថ្វាយ ទើបស្តេចដណ្តឹងថា នំនេះឈ្មោះនំអី ធ្នញ្ជ័យក្រាបទូលថា នេះហៅថានំបញ្ចុក បើនឹងស៊ីអោយងើយ ហើយហារមាត់លើកដៃអោយខ្ពស់ទើបបានស៊ីជាពិសា ឯនំនេះបានជាធនញ្ជ័យថាដូច្នោះ ត្បិតចង់ឃើញមុខស្តេចក្រុងចិន ត្បិតលឺតែព្រះបន្ទូល ឯព្រះភក្ត្រពុំដែលឃើញ ហើយចង់នឹងវិលមកស្រុកវិញ ឯស្តេចក្រុងចិនលឺដូច្នោះហើយក៏យកនំនោះមកថ្វាយហើយងើបដូចជាពាក្យធនញ្ជ័យថានោះឯង ឯធនញ្ជ័យកាលបើស្តេចសោយនំងើយឡើងហើយ ក៏មើលទៅឃើញមុខស្តេចក្រុងចិនហើយថា មើលមុខស្តេចក្រុងចិនឃើញខ្មៅអែ មើលមុខស្តេចស្រុកខ្មែរ ដូចខែពេញបូណ៌មី ឯមហាក្សត្រក្រុងចិនលឺធនញ្ជ័យដៀលដូច្នោះហើយ ក៏ទ្រង់នូវព្រះក្រោធខ្លាំងណាស់ ហើយត្រាស់ថាអោយអស់នាម៉ឺនចាប់យកទៅដាក់គុកសិរិទ្ធអោយដល់ស្លាប់កុំលែងវា ។

គុកនោះឯងត្រជាក់ណាស់ បើមនុស្សណាតែទៅដល់ហើយ ក៏ស្លាប់





មិនរស់ឡើយ កាលថ្ងៃដែលយកធនញ្ជ័យទៅដាក់គុកនោះមានចិន១នោះ
ខុស គេយកទៅដាក់គុកជាមួយនឹងធនញ្ជ័យ បានជាពីរនាក់នឹងចិននោះ
ឯគុកនោះតែដាកហើយមិនបាច់ដាក់ច្រវាក់ដាក់ឃ្នាងទេ តែទៅដល់ហើយ
ដោះចេញអស់ ទើបបញ្ចូលទៅក្នុងគុកនោះឯង ហើយទើបរាំងទ្វារទៅទុក
អោយស្លាប់ ឯធនញ្ជ័យដឹងជាងារត្រជាក់ណាស់ ហើយបបួលចិនទៅ
ប្រដាល់ចំបាប់អោយក្តៅបែកញើសស្រលខ្លួន ហើយវិលមកឈប់វិញ បើ
កាលណាវាត្រជាក់ណាស់ ក៏បបួលគ្នាទៅដាល់ៗតែសព្វថ្ងៃឥតមានរងារ
សោះឡើយ លុះបានពីរថ្ងៃបីថ្ងៃ អស់នាហ្មឺនអោយទៅមើលឃើញនៅរស់
ហើយវិលមកប្រាប់ថា អស់ទាំងអស់ទោសចិន និងខ្មែរនោះមិនស្លាប់ទេ បើ
ដូច្នោះតើនឹងធ្វើដូច្នោះ ទើបអស់នាហ្មឺនថា បើវាមិនស្លាប់ក៏ហើទៅចុះ ឯ
ធនញ្ជ័យហើយ និងចិនគិតថា យើងនឹងគិតធ្វើខ្លែងបង្ហើរ ធ្វើអែកអោយលឺតែ
យប់ ថ្ងៃដាក់ចេញ គិតឃើញធ្វើខ្លែងបានហើយ បង្ហើរសព្វយប់ បានលឺទៅ
ដល់ស្តេចៗលឺសូរសំលេងអែកនោះ វាប្លែកនឹងសំលេងសត្វយំ ស្តេចមិន
ដែលលឺដូច្នោះ ហើយស្តេចឆ្ងល់ក្នុងព្រះរាជហឫទ័យថា ថ្ងៃមិនដែលលឺមាត់
យំ តែយប់អន្ធឹតៗ តែសព្វយប់ ហើយស្តេចហៅនាហ្មឺនមកគិតថា មាន
នរណានឹងដឹងជាសត្វអ្វីវាយំនោះ ហើយស្តេចអោយហៅហោរមកគន់គូរ
មើល ឯហោរគន់គូរមើលទៅឃើញក្រាបទូលថា បានជាសត្វនេះវាយំ
ដូច្នោះ ត្បិតកើតហេតុក្នុងនគរ បើហេតុឧត្បាតនេះមិនឃើញ សត្វនោះវា
នឹងស៊ីអស់ទាំងរាស្ត្រក្នុងនគរនេះមិនខានឡើយ ស្តេចស្តាប់ហើយក៏មានព្រះ
បន្ទូលថា បើដូច្នោះ តើឧត្បាតពីព្រោះអ្វី ហោរគន់គូរមើលអោយបានដឹងក៏
នឹងធ្វើអោយជា កុំអោយសត្វនោះវាស៊ីមនុស្សរាស្ត្រប្រជាផងទាំងឡាយ
ទើបហោរក្រាបទូលថា ទូលព្រះបង្គំគិតទៅឃើញថា ត្បិតមានអ្នកប្រាជ្ញ១
គេយកពីស្រុកខ្មែរមកប្រោសចោលស្រុកះយើង ឥលូវនេះ ទ្រង់អោយដាក់
គុកនោះឯង បានជាកើតហេតុដូច្នេះឥលូវនេះ មានតែនឹងគិតអោយស្រុក
ខ្មែរវិញទើបជា ឯព្រះមហាក្សត្រស្តេចក្រុងចិនលឺហោរទូលដូច្នោះហើយ
ស្តេចភ្ញាក់ព្រះអង្គថា អញមិនដឹងជាអ្នកប្រាជ្ញស្រុកខ្មែរទេ មនុស្សស្រុកខ្មែរ
មិនដែលមកនៅរកស៊ីផ្ទេរផ្ទាសទេ បើដូច្នោះអោយទៅយកមកនឹងអង្វរ

សុំទោស កុំអោយខឹងនឹងអញឡើយ ឯអាមាត្យក៏រត់ទៅរកធនញ្ជ័យដែលនៅក្នុងគុកនោះឯងនាំមកថ្វាយស្តេចហើយ ឯព្រះមហាក្សត្រស្តេចស្តេចទតទៅឃើញធនញ្ជ័យមកដល់ហើយ ស្តេចមានព្រះបន្ទូលថា អញមិនដឹងជាខ្លួនឯងជាអ្នកប្រាជ្ញខ្មែរទេ ឥលូវនេះឯងកុំខឹងនឹងអញឡើយ អញនឹងយកមនុស្សចិនទាំងស្រីទាំងប្រុសបាន១០០ អញសែនឯង ហើយអោយជូនឯងទៅស្រុកវិញឯធញ្ជ័យក្រាបថ្វាយបង្គំទូលថា ខ្ញុំមិននឹងម្ចាស់ទេ សត្វដែលវាថានិងស៊ីរាស្ត្រនោះ ខ្ញុំម្ចាស់អោយវាទៅវិញហើយ ឯមហាក្សត្រស្រុកចិនដណ្តឹងថា ឈ្មោះសត្វអ្វីដែលវាយលឹកន្តឹតៗនោះ ទើបធនញ្ជ័យក្រាបទូលថា សត្វនោះឈ្មោះសត្វខ្លែង[1] ទើបស្តេចសួរថារូបវាដូចម្តេចក៏វាយំលឺខ្លាំងម្ល៉េះ ទើបធនញ្ជ័យក្រាបទូលថា ទូលព្រះបង្គំនឹងធ្វើរូបខ្លែងព្នងមកថ្វាយ ហើយធនញ្ជ័យទៅយកខ្លែងដែលបង្ហើរនោះមកថ្វាយ សត្វនេះវាយំនឹងស្នែងវាមិនបានយំនឹងមាត់វាដូចអស់ទាំងសត្វឯទៀតទេ ឯមហាក្សត្រស្តាប់ធនញ្ជ័យក្រាបទូលដូច្នោះហើយក៏មានព្រះបន្ទូលថា ប្លែកមិនដែលឃើញដូច្នេះ ទើបតែឥលូវនេះ បើដូច្នេះយើងធ្វើបង្ហើរអោយវាយំមើលលេង ហើយអោយយកសំពៅ១ធំចំនុះមនុស្ស២០០នាក់ ហើយនឹងជូនធនញ្ជ័យទៅស្រុកខ្មែរវិញ ហើយអោយយកមនុស្សចិនបាន១០០ ដាក់ក្នុងសំពៅហើយ ហើយនិងស្បៀងដាក់អោយជូនទៅជាសំណែនធនញ្ជ័យ ជូនមកស្រុក លុះដល់ហើយធនញ្ជ័យឡើងទៅសួរម្តាយឪពុកនូវប្រពន្ធ ហើយជញ្ជូនរបស់ដែលស្តេចក្រុងចិនព្រះរាជទានសែនជូនមកទាំងអស់នោះ អោយឡើងមកហើយអោយសង់ផ្ទះនៅជាសុខសប្បាយ បានជាមានចិននៅស្រុកខ្មែរ គេហៅថាចិនសំណែនធនញ្ជ័យទាល់តែឥលូវនេះ ។

ឯព្រះមហាក្សត្រស្រុកខ្មែរលឺថា ធនញ្ជ័យវិលមកវិញហើយ បានទាំងចិនមកផង ហើយស្តេចនូវនាហ្មឺនទាំងអស់កោតខ្លាចប្រាជ្ញាធនញ្ជ័យមិនហ៊ានធ្វើសេចក្តីអ្វីអោយទាស់នឹងគំនិតធនញ្ជ័យឡើយ ព្រះមហាក្សត្រអោយទៅហៅធញ្ជ័យមកសួរដណ្តឹងអំពីស្រុកចិន ត្បិតវាបានទៅ ធនញ្ជ័យក៏

១.សេកខះថា : សតត់នើយ៉វិង ។



ក្រាបទូលតាមដំណើរដែលបានទៅឃើញ ហើយនិយាយថា កាលខ្លួនខ្ញុំបានទៅដល់ហើយគិតអោយបានមកវិញនោះ ព្រោះធ្វើខ្លែងព្នងបង្ហើរ ស្តេចបានលឺសូរអែកខ្លែង បានជាខ្ញុំបានមកវិញ ឯព្រះមហាក្សត្រអោយធ្វើខ្លែងនោះបង្ហើរនឹងមើលលេង ធនញ្ជ័យក៏ធ្វើខ្លែងទៅថ្វាយអោយស្តេចទត ដូច្នេះឯងហៅខ្លែងព្នង បានជាយើងចេះធ្វើខ្លែងដល់ឥលូវនេះឯង ។

ឯធនញ្ជ័យដល់មានជំងឺឈឺខ្លាំងណាស់ ហើយផ្តាំប្រពន្ធថា បើអញនឹងស្លាប់ទៅហើយអោយយកទៅកប់នោះ អោយធ្វើចំរូងបោះលើផ្នូរនោះអោយច្រើនកុំអោយខាន ហើយអោយទៅទូលហ្លួងថា អញឈឺខ្លាំងណាស់ហើយ ឯប្រពន្ធនោះទៅទូលហ្លួងដូចពាក្យធនញ្ជ័យ ស្តេចដឹងដូច្នោះហើយក៏ស្តេចទៅសួរធនញ្ជ័យ ដល់ហើយស្តេចចូលទៅសួរធញ្ជ័យថា ឯងឈឺ តើដូចម្តេច ធនញ្ជ័យទូលថា សូមទ្រង់ចូលមកជិតខ្ញុំៗនឹងផ្តាំទុក ខ្ញុំទូលខ្លាំងមិនបានទេ ស្តេចស្តាប់ហើយចូលទៅជិត ធញ្ជ័យទូលថា សូមទ្រង់ឱនព្រះកេសមកជិតនឹងមាត់ខ្ញុំ ស្តេចក៏ឱនត្រចៀកទៅជិតមាត់ធនញ្ជ័យៗក៏ផ្តាំថា បើស៊ីត្រីព្រួលកុំចោលស្រកា បើស៊ីត្រីប្រាកុំចោលស្រកី អោយស្លក្បាលត្រីប្រានឹងម្ជូរសណ្តាន់ អោយស្តេចទុកកុំអោយភ្លេច ស្តេចស្តាប់ហើយវិលមកជំនាក់វិញ , ឯអស់នាហ្មឺនសួរហ្លួងថា ធនញ្ជ័យវាផ្តាំថាដូចម្តេច ព្រះមហាក្សត្រស្តេចស្តាប់ហើយ ក៏ប្រាប់អស់នាហ្មឺនថា តាមពាក្យធនញ្ជ័យថា ស៊ីត្រីព្រួលកុំចោលស្រកា ស៊ីត្រីប្រាកុំចោលស្រកី អោយស្លក្បាលត្រីប្រានឹងម្ជូរសណ្តាន់ វាថាជាលេងវាទេ ស្តេចមានព្រះបន្ទូលដូច្នោះ ក៏អស់នាហ្មឺនមិនជឿឡើយ គិតថាថាធនញ្ជ័យនេះជាអ្នកប្រាជ្ញធំណាស់ ដឹងជាគេថាដូចម្តេចនឹងព្រះមហាក្សត្រ ។ កាលធនញ្ជ័យស្លាប់ទៅ គេក៏យកទៅកប់ ហើយធ្វើចំរូងដោតផ្នូរនោះ តាមពាក្យធនញ្ជ័យនោះឯង អស់នាម៉ឺននូវអ្នកក្នុងវាំងដែលខឹងស្អប់ធនញ្ជ័យថា ធញ្ជ័យនោះយកប្រាក់ លឺថាធនញ្ជ័យស្លាប់ហើយ គេយកទៅ

កប់នៅទីត្រង់ណា ក៏ប្រើមនុស្សជុះអាចម៍ដាក់ផ្នូរ ឯអស់មនុស្សទាំងនោះក៏ទៅដល់ផ្នូរ ហើយក៏សើយសំពត់ដាក់គូទនឹងជុះ មិនបានដឹងថាមានចំរូងវាគូទរាល់គ្នា រាងមិនហ៊ានទៅទៀតឡើយ ហើយខ្លាចធនញ្ជ័យ ក៏ស្រដីប្រាប់គ្នារៀងទៅ នេះប្រាកដជាអ្នកមានប្រាជ្ញថា ដល់ស្លាប់ទៅហើយក៏គង់គិតទុកអោយបានគង់ដឹងជា ឯងទៅជុះអាចម៍ដាក់ផ្នូរគាត់ បានជាមានផ្តាំអោយគេទៅដោតចំរូងទុកអោយមុតគូទឯង ៕

❖ ចប់ ❖